## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

## ៣-ការវិភាគគំលាតចំណេញដុល

រ.ទ.ស.ភ. បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមប្រភេទ ដូចនេះពុំមានការបង្ហាញឲ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឲ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ។

ចំណាយប្រត្តិបត្តិការនឹងលើកយកមកពិភាក្សានៅចំណុចទី៤- ការចំណេញមុនបង់ពន្ធខាងក្រោម។

## ៤- ការចំណេញមុនបង់ពន្ធ

ការចំណេញមុនបង់ពន្ធគឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ និងចំណូល/(ចំណាយ) ការប្រាក់សុទ្ធ។ ក្នុងការពិភាក្សានិងការវិភាគនៃចំណាយប្រតិបត្តិការ យើងលើកយកចំណាយសរុបរួមយកមកពិភាក្សាដូចខាងក្រោម៖

➢ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩**

| | **ត្រីមាសទី១ ឆ្នាំ២០២០ (ពាន់រៀល)** | **ត្រីមាសទី១ ឆ្នាំ២០១៩ (ពាន់រៀល)** | **បម្រែបម្រួល (ពាន់រៀល/ភាគរយ)** | |
|---|---|---|---|---|
| ចំណូលសរុប | ៧៥.៨១៧.៣១៦ | ៥៥.២៥៨.៩៤៧ | ២០.៥៥៨.៣៦៩ | ៣៧,២០% |
| ចំណាយសរុប | ៤៤.៣៥៦.៥៤៦ | ៣៨.៣៣១.៧១៤ | ៦.០២៤.៨៣២ | ១៥,៧២% |
| ចំណូលការប្រាក់ | ២.៥១១.៤៤៨ | ២.៨៥៣.៦៣៨ | (៣៤២.១៩០) | (១១,៩៩%) |
| ចំណាយការប្រាក់ | ៨១៥.៣០៥ | ១.៨៧៦.៦០៦ | (១.០៦១.៣០១) | (៥៦,៥៥%) |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | ៣៣.១៥៦.៩១៣ | ១៧.៩០៤.២៦៥ | ១៥.២៥២.៦៤៨ | ៨៥,១៩% |

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានចំណេញមុនបង់ពន្ធលើប្រាក់ចំណេញចំនួន៣៣.១៥៦.៩១៣.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ និង១៧.៩០៤.២៦៥.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ ដែលមានទឹកកើនឡើងចំនួន១៥.២៥២.៦៤៨.០០០រៀល ស្មើនឹង៨៥,១៩%។

យើងឃើញថាកត្តានៃការកើនឡើងនេះគឺដោយសារ ចំណូលសរុបមានការកើនឡើងចំនួន២០.៥៥៨.៣៦៩.០០០រៀល ស្មើនឹង៣៧,២០% ទន្ទឹមនឹងនោះចំណូល-ចំណាយការប្រាក់សុទ្ធក៏បាន កើនឡើងចំនួន៧១៩.១១១.០០០រៀល ស្មើនឹង៧៣,៦០% ទោះបីជាការចំណាយ បានកើនឡើងប្រមាណ១៥,៧២% ស្មើនឹង ៦.០២៤.៨៣២.០០០រៀល។

## ៥- ការវិភាគចំណេញក្នុងការិយបរិច្ឆេទ

រ.ទ.ស.ភ. ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារនិងអាករ ដូចនេះ រ.ទ.ស.ភ. មានកាតព្វកិច្ចត្រូវបង់ពន្ធលើប្រាក់ចំណេញជាប់ពន្ធនូវអត្រា២០%។ ដោយឡែកពន្ធលើប្រាក់ចំណេញដែលជាប់អត្រា២០% បានមកពីលទ្ធផលនៃប្រាក់ចំណេញគណនេយ្យ ទូទាត់ជាមួយនឹងចំណាយដែលមិនអាចកាត់កងបានក្នុងអត្រាពន្ធ ២០%។

➢ **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩**

| | **ត្រីមាសទី១ ឆ្នាំ២០២០ (ពាន់រៀល)** | **ត្រីមាសទី១ ឆ្នាំ២០១៩ (ពាន់រៀល)** | **បម្រែបម្រួល (ពាន់រៀល/ភាគរយ)** | |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ (ក) | ៣៣.១៥៦.៩១៣ | ១៧.៩០៤.២៦៥ | ១៥.២៥២.៦៤៨ | ៨៥,១៩% |
| ចំណាយពន្ធលើប្រាក់ចំណេញ (ខ) | ៦.៥៥២.៩៦៩ | ៩.៤៧៦.២០៣ | (២.៩២៣.២៣៤ ) | (៣០,៨៥%) |
| ចំណេញក្នុងគ្រា | ២៦.៦០៣.៩៤៤ | ៨.៤២៨.០៦២ | ១៨.១៧៥.៨៨២ | ២១៥,៦៦% |
| អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ (ខ)/(ក) | ១៩,៧៦% | ៥២,៩៣% | | |